Post in All Classrooms

# San Diego Unified School District

## មាតាបិតា, អ្នកអាណាព្យាបាលសិស្ស, លោកគ្រូ-អ្នកគ្រូ ព្រមទាំងសិស្សានុសិស្សប្រុងប្រយ័ត្ន

## ពត៌មានសំខាន់ស្តីអំពី សម្ភារៈបង្រៀន, អាគារសាលារៀន និងលោកគ្រូ-អ្នកគ្រូ

តាម**ច្បាប់អប់រំ**ប្រចាំរដ្ឋ California មាត្រា ៣៥១៨៦ តម្រូវឡើងថា លោកអ្នកទាំងអស់គួរតែជ្រាបពត៌មានដូចតទៅ:

១. នៅតាមសាលារៀនត្រូវមានសៀវភៅសំរាប់សិស្សសិក្សា ព្រមទាំងសម្ភារៈសំរាប់សិក្សាគ្រប់គ្រាន់។ នោះមានន័យថា សិស្សម្នាក់ៗ រួមនឹងសិស្សរៀន អង់គ្លេស ត្រូវតែមានសៀវភៅសិក្សា ឬសម្ភារៈសិក្សា ឬទាំងពីរផ្នែកនេះ សំរាប់ប្រើប្រាស់នៅតាមថ្នាក់រៀន និងយកទៅផ្ទះសិក្សា។

២. អាគារសាលារៀនត្រូវតែមានអនាម័យស្អាតបាត, មានសន្តិសុខ និងមានជួសជុលអោយបានល្អ។

៣. ការមិនមានគ្រូបង្រៀនជាក់លាក់នៅតាមសាលារៀន ឬចំណាត់ការបង្រៀនមិនបានត្រឹមត្រូវ។ គ្រូត្រូវចាត់អោយបង្រៀននៅតាម ថ្នាក់រៀននិមួយៗ និងមិនត្រូវអោយមានគ្រូជំនួស ឬគ្រូបង្រៀនជាបណ្តោះអាសន្ននៅតាមបន្ទប់រៀនឡើយ។ គ្រូត្រូវតែមានសញ្ញាប័ត្រផ្នែកបង្រៀនត្រឹមត្រូវតាមច្បាប់ ដើម្បីបង្រៀននៅតាមថ្នាក់រៀននិមួយៗ។ ព្រមទាំងត្រូវមានសញ្ញាប័ត្រតម្រូវអោយបង្រៀនសិស្សរៀន អង់គ្លេស បើមានសិស្សរៀន អង់គ្លេស។

   ការមិនមានគ្រូបង្រៀនជាក់លាក់នៅតាមសាលារៀនមានន័យថា មិនមានគ្រូមានសញ្ញាប័ត្រចាត់អោយបង្រៀននៅតាមថ្នាក់រៀន ចាប់ពីដើមឆ្នាំរហូតដល់ចុងឆ្នាំ ឬបើមានចាត់អោយបង្រៀនតែមួយឆមាស ហើយមិនបានចាត់អោយចាប់ផ្តើបង្រៀននាដើមឆមាស ឬបង្រៀនរហូតដល់ចប់មួយឆមាស។

   ចំណាត់ការបង្រៀនមិនបានត្រឹមត្រូវមានន័យថា ការចាត់អោយបុគ្គលិកការងារធ្វើការបង្រៀនមិនបានត្រឹមត្រូវតាមមុខងារ ឬកិច្ចការ ឬតាមសមត្ថភាព ឬតាមកកិច្ចការបង្រៀនរបស់ខ្លួន។

៤. សិស្សណាដែលប្រឡងវិញ្ញាសារវិទ្យាល័យ (high school examination) មួយផ្នែក ឬទាំងពីរផ្នែកនេះមិនជាប់រហូតរៀនចប់ថ្នាក់ទី ១២ នឹងបានទទួលការបង្រៀន និងការបំរើច្រើនបន្ថែមពីរឆ្នាំជាប់ៗគ្នា ក្រោយពេលរៀនចប់ថ្នាក់ទី ១២ ឬរហូតទាល់តែប្រឡងវិញ្ញាសារទាំងពីរមុខនេះអោយបានជាប់ ឬមួយណាក៏បានដែរ។

បើលោកអ្នកយល់ថាសាលារៀនមិនប្រតិបត្តិតាមគោលការនេះទេ លោកអ្នកអាចសុំទម្រង់តវ៉ាដែលមាននៅតាមការិយាល័យប្រចាំសាលារៀននិមួយៗឬការិយាល័យក្រសួងអប់រំផ្នែកណែនាំទូទៅដែលមានអស័យដ្ឋាន: 4100 Normal Street Room 2148, San Diego, CA 92103 ដើម្បីធ្វើការតវ៉ាបាន។ លោកអ្នកអាចចម្លងទម្រង់តវ៉ាចេញពីប្រព័ន Web site របស់ក្រសួងអប់រំប្រចាំ California បាន http://www.cde.ca.gov/re/cp/uco.

Revised per AB 347 January 2008

Attention parents, guardians, teachers, and students. Cambodian Version.